ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រឹត្តិបត្រស្ថិតិ
# សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ប្រចាំត្រីមាសទី៣ ឆ្នាំ២០២២

អគ្គនាយកដ្ឋានគោលនយោបាយ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ខែវិច្ឆិកា ឆ្នាំ ២០២២

# មាតិកា


សេចក្តីអធិប្បាយសង្ខេប........................................................................១

តារាងស្ថិតិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ.................................................................៤

១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ..............................................................................៤

២. សូចនាករតាមវិស័យ.......................................................................................៦

២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់........................................................................ ៦

២.២. អត្រាប្តូរប្រាក់..........................................................................................៧

២.៣. ហិរញ្ញវត្ថុសាធារណៈ................................................................................... ៨

២.៤. ស្ថានភាពរូបិយវត្ថុ និងឥណទាន.....................................................................១០

២.៥. ស្ថានភាពពាណិជ្ជកម្ម.................................................................................១៤

២.៦. ការវិនិយោគឯកជន ......................................................................................១៨

២.៧. ស្ថានភាពទេសចរណ៍....................................................................................១៩

២.៨. ស្ថានភាពសំណង់ ...................................................................................... ២១

៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ ........................................... ២២

# សេចក្តីអធិប្បាយសង្ខេប

សេដ្ឋកិច្ចសកល បាននិងកំពុងងើបឡើងបណ្តើរៗ ដែលរំពឹងថានឹងសម្រេចបានកំណើន ៣,២% ក្នុងឆ្នាំ២០២២[1] ដោយប្រទេសភាគច្រើន បាននិងកំពុងជំរុញវិធានការគោលនយោបាយស្តារសេដ្ឋកិច្ចឡើងវិញ, ពន្លឿនការចាក់វ៉ាក់សាំងបន្ថែម និងធ្វើអន្តរាគមន៍នានា ដើម្បីបន្តបង្កើនភាពស៊ាំសហគមន៍រឹងមាំ និងការរស់នៅក្នុងគន្លងប្រក្រតីភាពថ្មី (New Normal) ។ ទោះជាយ៉ាងនេះក្តី, កំណើនសេដ្ឋកិច្ចសកលនៅឆ្នាំ២០២៣ នឹងមានកំណើនត្រឹមតែ ២,៧% ទាបជាងការព្យាករណ៍កន្លងមក ដោយសារការថមថយកំណើននៃសេដ្ឋកិច្ចចិន សហរដ្ឋអាមេរិក និងអឺរ៉ុប, ការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុសកល, ការអូសបន្លាយនៃសង្គ្រាមនៅអ៊ុយក្រែន និងការលេចឡើងនូវជំងឺកូវីដ-១៩ បំប្លែងថ្មី (New Variants) ដែលធ្វើឱ្យរំខាន និងបង្កភាពរអាក់រអួលនៃខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងសេដ្ឋកិច្ច ក៏ដូចជាបានធ្វើឱ្យអត្រាអតិផរណា, ថ្លៃប្រេងឥន្ធនៈ, ថ្លៃម្ហូបអាហារ និងថ្លៃទំនិញមួយចំនួនទៀត មានការកើនឡើងខ្ពស់ ។

ទន្ទឹមនេះ, សេដ្ឋកិច្ចកម្ពុជា ត្រូវបានរំពឹងថានឹងរក្សាបានកំណើន ៥,៤% ក្នុងឆ្នាំ២០២២នេះ បើទោះបីជារងការប៉ះទង្គិច ដោយប្រយោលពីការផ្ទុះឡើងនៃសង្គ្រាមនៅអ៊ុយក្រែន ក៏ដោយ ។ ការរក្សាបានកំណើននេះ គឺដោយសារតែទីផ្សារធំៗ របស់កម្ពុជា នៅតែមានតម្រូវការ ព្រមទាំងសកម្មភាពធុរកិច្ច និងខ្សែច្រវាក់ផ្គត់ផ្គង់ផលិតកម្មក្នុងស្រុក មានភាពល្អប្រសើរ ។ រាជរដ្ឋាភិបាល បានបន្តអនុវត្តវិធានការអន្តរាគមន៍ ដូចជា ការឧបត្ថម្ភសាច់ប្រាក់ដល់ប្រជាជនងាយរងគ្រោះ និងការផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករ-និយោជិតក្នុងអំឡុងពេលព្យួរការងារ ជាដើម ។ ក្នុងត្រីមាសទី៣ ឆ្នាំ២០២២នេះ, ស្ថានភាពសេដ្ឋកិច្ចកម្ពុជា បាននិងកំពុងងើបឡើង តាមរយៈការកើនឡើងនៃភ្ញៀវទេសចរអន្តរជាតិ, គម្រោងសាងសង់, គម្រោងវិនិយោគលើវិស័យឧស្សាហកម្ម-សេវាកម្ម និងការបន្តកើនឡើងនូវផលិតកម្មក្នុងស្រុក ស្របពេលដែលការនាំចេញបន្តមានកំណើនល្អ លើផលិតផលកាត់ដេរ និងផលិតផលមិនមែនកាត់ដេរ ដូចជា កង់, ខ្សែភ្លើងនិងបង្គុំខ្សែភ្លើង, គ្រឿងបង្គុំរថយន្ត និងផលិតផលផ្សេងៗមួយចំនួនទៀត ។

**អតិផរណា និង អត្រាប្តូរប្រាក់**[2]

អតិផរណាមធ្យមប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ មានអត្រា ៤,៩% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២១ ក្នុងនោះ សន្ទស្សន៍ថ្លៃសាច់ជ្រូកបានកើនឡើង ៥,៧%, ត្រី ៤,៥%, ប្រេងម៉ាស៊ូត ៣៨,៥%, ប្រេងសាំងធម្មតា ១៣,៦% និងឧស្ម័ន (Gas) ១៦,៧% ។ ទន្ទឹមនេះ, អត្រាប្តូរប្រាក់ជាមធ្យមក្នុងរង្វង់ ៤ ០៩៥,២ រៀល/ ដុល្លារអាមេរិក បានកើនឡើង ០,៥% ។

**ស្ថានភាពហិរញ្ញវត្ថុសាធារណៈ**[3]

នៅត្រីមាសទី៣ ឆ្នាំ២០២២, ការប្រមូលចំណូលសរុបអនុវត្តបានចំនួន ៥ ៧៨៨ ប៊ីលានរៀល (ស្មើ ២៦% នៃច្បាប់ថវិកាប្រចាំឆ្នាំ) បានកើនឡើង ៣៥,១% ក្នុងនោះ ចំណូលចរន្តសរុប ៥ ៧៧៤ ប៊ីលានរៀល បានកើនឡើង ៣៥,៣ % ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២១ ។ កំណើននេះ គាំទ្រដោយពន្ធលើប្រាក់ចំណូលនិងប្រាក់ចំណេញ, ពន្ធលើទំនិញនិងសេវាប្រើប្រាស់, ពន្ធលើពាណិជ្ជកម្មអន្តរជាតិ និងចំណូលមិនមែនពន្ធ តាមរយៈការបន្តពង្រឹកមូលដ្ឋានពន្ធ, ការធ្វើទំនើបកម្មរូបនីយកម្ម,

[1] ការប៉ាន់ស្មានរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ចេញផ្សាយកាលពីខែតុលា ឆ្នាំ២០២២

[2] ទិន្នន័យពីវិទ្យាស្ថានជាតិស្ថិតិ/ ក្រសួងផែនការ និងធនាគារជាតិ នៃកម្ពុជា

[3] ទិន្នន័យពីអគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ការអនុវត្តវិធានការកែទម្រង់, និងនិន្នាការងើបឡើងវិញ នៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ។ ជារួម កំណើនចំណូលនេះ បានធ្វើឱ្យថវិកាចរន្តមានអតិរេកចំនួន ១ ៦១២,២ ប៊ីលានរៀល ។ រីឯ, ចំណាយសរុបអនុវត្តបាន ៥ ៧០៩,១ ប៊ីលានរៀល (ស្មើនឹង ១៨,៤% នៃច្បាប់ថវិកាប្រចាំឆ្នាំ) បានធ្លាក់ចុះ ១៤,៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២១ កន្លងទៅ ក្នុងនោះ ចំណាយចរន្តសរុបចំនួន ៤ ១៦១,៨ ប៊ីលានរៀល បានធ្លាក់ចុះ ៨,៩% និងចំណាយមូលធន បានធ្លាក់ចុះ ២៦,៩% ដោយសារធ្វើវិចារណកម្មចំណាយ ឈរលើគោលការណ៍រឹតបន្តឹងចំណាយមិនចាំបាច់នានា និងវិភាជថវិកាសម្រាប់អនុវត្តឱ្យចំមុខសញ្ញាប្រកបដោយបុរេសកម្ម បន្តដោះស្រាយផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា ។

**ស្ថានភាពរូបិយវត្ថុ និងឥណទាន**[4]

គិតត្រឹមត្រីមាសទី៣ ឆ្នាំ២០២២, រូបិយវត្ថុទូទៅ (M2) សរុបមានចំនួន ១៦៩,៤ ទ្រីលានរៀល បានកើនឡើង ១០,៧% ខណៈទុនបម្រុងរូបិយបណ្ណបរទេសដុល សរុបមានចំនួន ១៧,៧ ប៊ីលានដុល្លារអាមេរិក បានធ្លាក់ចុះ ១០,៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២១ ។ ទន្ទឹមនេះ ឥណទានដែលផ្តល់ដោយធនាគារពាណិជ្ជមានចំនួន ១៨៨,៨ ទ្រីលានរៀល បានកើនឡើង ២៤,៥% ដែលភាគច្រើនបានផ្តល់ជូនទៅគ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ ។

**ពាណិជ្ជកម្មក្រៅប្រទេស**[5]

នៅត្រីមាសទី៣ ឆ្នាំ២០២២, ការនាំចេញទំនិញមានទឹកប្រាក់សរុបចំនួន ៥ ៦១៤,៦ លានដុល្លារអាមេរិក បានកើនឡើង ៤,៨% និងការនាំចូលទំនិញមានទឹកប្រាក់សរុបចំនួន ៧ ៨៩៩,៥ លានដុល្លារអាមេរិក បានកើនឡើង ២២,៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២១ ។ បើមិនរាប់បញ្ចូលមាស, ការនាំចេញមានទឹកប្រាក់សរុបចំនួន ៥ ៥៦៧,៧ លានដុល្លារអាមេរិក បានកើនឡើង ៤,៣% ដែលបានគាំទ្រដោយការនាំចេញសម្លៀកបំពាក់, ស្បែកជើង, កាបូប, កង់, ខ្សែភ្លើងនិងបង្គុំខ្សែភ្លើង, គ្រឿងបង្គុំរថយន្ត និងផលិតផលផ្សេងៗមួយចំនួនទៀត ។ ទន្ទឹមនេះ ការនាំចូលមានទឹកប្រាក់សរុបចំនួន ៦ ៣៥១,៨ លានដុល្លារអាមេរិក បានកើនឡើង ៩,២% ដោយសារការកើនឡើងនៃការនាំចូលប្រេងឥន្ធនៈ, យានយន្ត, គ្រឿងអេឡិចត្រូនិក, គ្រឿងបង្គុំរថយន្ត និងគ្រឿងឧបភោគបរិភោគ ជាដើម ។

**ទេសចរណ៍**[6]

នៅត្រីមាសទី៣ ឆ្នាំ២០២២, ភ្ញៀវទេសចរអន្តរជាតិសរុបមានចំនួន ៧៥៩ ០១០ នាក់ បានកើនឡើងប្រមាណជា ២៦ ដង ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២១ ។ កំណើននេះ ដោយសារការបន្ធូរបន្ថយនីតិវិធីធ្វើដំណើរពីបរទេស, ការពង្រីកវិសាលភាពនៃការចាក់វ៉ាក់សាំង, ការបង្កើតបាននូវភាពស៊ាំសហគមន៍ ដែលបានអនុញ្ញាតឱ្យសកម្មភាពសង្គម-សេដ្ឋកិច្ច ដំណើរការឡើងវិញ និងត្រលប់ទៅរកនិន្នាការធម្មតាក្នុងគន្លងប្រក្រតីភាពថ្មី ។

---

[4] ទិន្នន័យពីធនាគារជាតិ នៃកម្ពុជា

[5] ទិន្នន័យពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

[6] ទិន្នន័យពីក្រសួងទេសចរណ៍

**ការវិនិយោគឯកជន**[7]

នៅត្រីមាសទី៣ ឆ្នាំ២០២២, គម្រោងវិនិយោគដែលបានអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សរុបចំនួន ៥២ គម្រោង បានកើនឡើង ៥ គម្រោង ស្មើនឹង ១០,៦% និងទុនវិនិយោគសរុបចំនួន ៤៦០,៨ លានដុល្លារអាមេរិក បានកើនឡើង ១៨,៤% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២១ ។ ជាការសង្កេតការកើនឡើងនេះ គឺដោយសារកំណើនគម្រោងការវិនិយោគលើការផលិតបន្ទះសូឡា, ការសាងសង់មន្ទីរពេទ្យ, ការដំឡើងរថយន្ត, គម្រោងអភិវឌ្ឍន៍តាមកោះ និងការពង្រីកគម្រោងមួយចំនួនទៀត ក្នុងតំបន់សេដ្ឋកិច្ចពិសេស ។

**សំណង់**[8]

នៅត្រីមាសទី៣ ឆ្នាំ២០២២, ការអនុម័តលើសំណើគម្រោងសាងសង់ សរុបមានចំនួន ១ ១៧៥ គម្រោង បានកើនឡើង ១៤៧ គម្រោង ស្មើនឹង ១៤,៣% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះ ការកើនឡើង នៃគម្រោងប្រភេទសំណង់លំនៅឋាន-ភូមិគ្រឹះ, សំណង់ឧស្សាហកម្ម, សំណង់សាធារណៈ (ថវិកាពីវិស័យឯកជន), និងសំណង់ផ្សេងៗ លើកលែងតែប្រភេទសំណង់ពាណិជ្ជកម្ម និងទេសចរណ៍ ។ ទន្ទឹមនេះ វិស័យសំណង់ រំពឹងថានឹងងើបឡើងវិញ ក្នុងអត្រា ៣% នៅក្នុងឆ្នាំ២០២២នេះ ដោយសារកំណើនការផ្តល់ឥណទានលើវិស័យសំណង់ បានបន្តកើនឡើង ។

**ថ្លៃទំនិញសំខាន់ៗ**[9] **លើទីផ្សារអន្តរជាតិ**

នៅត្រីមាសទី៣ ឆ្នាំ២០២២នេះ, ថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ គិតជាមធ្យម ដូចជា ប្រេងឆៅ ៩៦,៤ ដុល្លារអាមេរិក/ ធុង បានកើនឡើង ៣៤,៦%, អង្ករ ៤២៩,៣ ដុល្លារអាមេរិក/ តោន បានកើនឡើង ៥,៨% ខណៈដែលមាស ១ ៨៩៣,៧ ដុល្លារអាមេរិក/ អោន បានធ្លាក់ចុះ ៣,៥% និងកៅស៊ូ (TSR20) ១ ៤៤៧ ដុល្លារអាមេរិក/ តោន បានធ្លាក់ចុះ ១២,៥% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។ ទន្ទឹមនេះ សន្ទស្សន៍ថ្លៃថាមពលគិតជាមធ្យម ១៦៥,៧ បានកើនឡើង ៦៦,១%, មិនមែនថាមពល ១១៦,១ បានកើនឡើង ៣,២% ខណៈលោហធាតុមានតម្លៃ ១២៩,៥ បានធ្លាក់ចុះ ៦,៥% ។

---

[7] ទិន្នន័យពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)

[8] ទិន្នន័យពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

[9] ទិន្នន័យពីគេហទំព័រធនាគារពិភពលោក និងសម្គាល់÷សន្ទស្សន៍ថ្លៃថាមពល (ធ្យូងថ្ម, ប្រេងឆៅ និងឧស្ម័ន), មិនមែនថាមពល (លោហធាតុ, កសិកម្ម និងជីគីមី) និងលោហធាតុមានតម្លៃ(មាស, ប្រាក់ និងប្លាទីន)

# តារាងស្ថិតិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ

*តារាង ១÷ ទិន្នន័យសេដ្ឋកិច្ចសំខាន់ៗ*

| បរិយាយ | ឯកតា | ត្រីមាសទី៣ | | | ការប្រែប្រួល |
|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | ២០២២ |
| **សូចនាករម្ភូលដ្ឋាន** | | | | | |
| អតិផរណា (ជាមធ្យម) | % | 2.8% | 3.2% | 4.9% | |
| អត្រាប្តូរប្រាក់ (ជាមធ្យម) | រៀល/ ដុល្លារអាមេរិក | 4,094.59 | 4,076.33 | 4,095.24 | 0.5% |
| **ហិរញ្ញវត្ថុសាធារណៈ** | | | | | |
| ចំណូលចរន្ត | ប៊ីលានរៀល | 4,150.53 | 4,268.27 | 5,773.98 | 35.3% |
| ចំណាយចរន្ត | ប៊ីលានរៀល | 3,849.51 | 4,567.11 | 4,161.80 | -8.9% |
| តុល្យភាពថវិកាចរន្ត | ប៊ីលានរៀល | 301.02 | (298.84) | 1,612.19 | -639.5% |
| **រូបិយវត្ថុ និងឥណទាន** | | | | | |
| រូបិយវត្ថុទូទៅ (M2) | ប៊ីលានរៀល | 132,613.63 | 152,996.61 | 169,403.64 | 10.7% |
| ឥណទាន* | ប៊ីលានរៀល | 150,448.32 | 185,124.77 | 226,038.92 | 22.1% |
| ឥណទេយ្យក្នុងស្រុក | ប៊ីលានរៀល | 117,918.31 | 159,673.10 | 197,698.93 | 23.8% |
| ទុនបម្រុងរូបិយបណ្ណបរទេសសុទ្ធ | លានដុល្លារអាមេរិក | 20,470.24 | 19,693.70 | 17,663.57 | -10.3% |
| **ពាណិជ្ជកម្មអន្តរជាតិ** | | | | | |
| ទំហំនាំចេញ | លានដុល្លារអាមេរិក | 5,525.09 | 5,359.23 | 5,614.61 | 4.8% |
| ទំហំនាំចូល | លានដុល្លារអាមេរិក | 4,322.05 | 6,445.72 | 7,899.54 | 22.6% |
| តុល្យភាពពាណិជ្ជកម្ម | លានដុល្លារអាមេរិក | 1,203.04 | (1,086.50) | (2,284.93) | 110.3% |
| **វិនិយោគឯកជន** | | | | | |
| គម្រោងវិនិយោគសរុប | គម្រោង | 29 | 40 | 52 | 10.6% |
| ទុនវិនិយោគ | លានដុល្លារអាមេរិក | 3,788.19 | 389.06 | 460.77 | 18.4% |
| **ទេសចរណ៍** | | | | | |
| ភ្ញៀវទេសចរអន្តរជាតិ | នាក់ | 64,854 | 29,114 | 759,010 | 2507.0% |

| បរិយាយ | ឯកតា | ត្រីមាសទី៣ | | | ការប្រែប្រួល |
|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | ២០២២ |
| **សំណង់** | | | | | |
| គម្រោងអនុញ្ញាត | គម្រោង | 1,217 | 1,028 | 1,175 | 14.3% |
| តម្លៃសំណង់ | លានដុល្លារអាមេរិក | 2,025.34 | 1,885.56 | 752.76 | -60.1% |
| **ថ្លៃទំនិញលើទីផ្សារអន្តរជាតិ (ជាមធ្យម)** | | | | | |
| អង្ករ (បាក់៥%) | ដុល្លារអាមេរិក/ តោន | 497.33 | 405.67 | 429.33 | 5.8% |
| ប្រេងឆៅ** | ដុល្លារអាមេរិក/ ធុង | 42.04 | 71.65 | 96.43 | 34.6% |
| កៅស៊ូ (TSR20) | ដុល្លារអាមេរិក/ តោន | 1,297.40 | 1,654.37 | 1,447.03 | -12.5% |
| មាស | ដុល្លារអាមេរិក/ អោន | 2,098.12 | 1,963.24 | 1,893.69 | -3.5% |

ប្រភព÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ និងធនាគារជាតិនៃកម្ពុជា

សម្គាល់÷ *ឥណទានផ្តល់ដោយធនាគារពាណិជ្ជ និងមីក្រូហិរញ្ញវត្ថុ, ** ថ្លៃជាមធ្យមរួមប្រេងឆៅ÷ Brent, WTI និង Dubai

# ២. សូចនាករតាមវិស័យ

## ២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

*តារាង ២៖ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (មធ្យមប្រចាំត្រីមាស)*

| បរិយាយ | ត្រីមាសទី៣ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២២ |
| **មុខទំនិញគ្រប់មុខ** | **183.1** | **189.0** | **198.3** | **4.9%** |
| អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង | 227.0 | 234.0 | 244.8 | 4.6% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | 174.6 | 177.0 | 179.0 | 1.2% |
| សម្លៀកបំពាក់ និងស្បែកជើង | 156.2 | 165.2 | 175.9 | 6.5% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | 129.4 | 133.0 | 139.8 | 5.1% |
| គ្រឿងសង្ហារិម សម្ភារប្រើប្រាស់ និងការថែទាំ | 153.2 | 155.4 | 160.9 | 3.5% |
| សុខាភិបាល | 137.1 | 139.7 | 142.0 | 1.7% |
| ការដឹកជញ្ជូន | 108.6 | 119.9 | 128.4 | 7.2% |
| គមនាគមន៍ | 66.6 | 66.5 | 66.5 | 0.0% |
| ការកំសាន្ត និងវប្បធម៌ | 120.4 | 120.9 | 128.6 | 6.3% |
| ការសិក្សា | 165.5 | 164.9 | 169.0 | 2.5% |
| ភោជនីយដ្ឋាន | 298.6 | 300.8 | 322.4 | 7.2% |
| ទំនិញ និងសេវាកម្មផ្សេងៗ | 154.6 | 162.0 | 166.6 | 2.8% |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ (ឆ្នាំគោល ២០០៦)

*រូបភាព ១៖ ស្ថានភាពអតិផរណា (មធ្យមប្រចាំត្រីមាស)*




ប្រភព: វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

## ២.២. អត្រាប្តូរប្រាក់

*តារាង ៣៖ អត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)*

| អត្រាប្តូរប្រាក់មធ្យមប្រចាំខែ | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
|---|---|---|---|---|
| 2015 | 4,042.67 | 4,055.67 | 4,092.00 | 4,050.67 |
| 2016 | 4,022.67 | 4,054.67 | 4,094.38 | 4,041.72 |
| 2017 | 4,016.14 | 4,047.37 | 4,079.54 | 4,037.16 |
| 2018 | 4,011.98 | 4,046.47 | 4,073.46 | 4,047.26 |
| 2019 | 4,006.33 | 4,052.39 | 4,086.61 | 4,063.09 |
| 2020 | 4,064.19 | 4,087.18 | 4,094.59 | 4,063.76 |
| 2021 | 4,059.51 | 4,063.00 | 4,076.33 | 4,072.03 |
| 2022 | 4,063.26 | 4,056.07 | 4,095.2 | |

*ប្រភព: ធនាគារជាតិនៃកម្ពុជា*

*រូបភាព ២៖ ស្ថានភាពអតិផរណា និងអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)*




ប្រភព: ធនាគារជាតិនៃកម្ពុជា

## ២.៣. ហិរញ្ញវត្ថុសាធារណៈ

*តារាង ៤៖ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) (គិតជាប៊ីលានរៀល)*

| បរិយាយ | ត្រីមាសទី៣ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២២ |
| **I. ចំណូលក្នុងប្រទេស** | **4,190.37** | **4,282.79** | **5,787.97** | **35.1%** |
| **១. ចំណូលចរន្ត** | **4,150.53** | **4,268.27** | **5,773.98** | **35.3%** |
| ក. ចំណូលសារពើពន្ធ | 3,886.76 | 3,993.66 | 5,200.02 | 30.2% |
| ខ. ចំណូលមិនមែនសារពើពន្ធ | 263.76 | 274.61 | 573.96 | 109.0% |
| **២. ចំណូលមូលធន** | **39.84** | **14.51** | **13.99** | **-3.6%** |
| **II. ចំណាយសរុប** | **5,982.16** | **6,684.42** | **5,709.05** | **-14.6%** |
| **១. ចំណាយចរន្ត** | **3,849.51** | **4,567.11** | **4,161.80** | **-8.9%** |
| ក. ការពារ និងសន្តិសុខជាតិ | 1,070.19 | 995.09 | 1,018.65 | 2.4% |

| បរិយាយ | ត្រីមាសទី៣ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២២ |
| ខ. រដ្ឋបាលស៊ីវិល | 2,590.70 | 3,390.13 | 2,933.34 | -13.5% |
| គ. ចំណាយការប្រាក់ | 188.61 | 181.89 | 209.81 | 15.3% |
| **២. ចំណាយមូលធន** | **2,132.66** | **2,117.30** | **1,547.25** | **-26.9%** |
| ឱនភាពចរន្ត (សាច់ប្រាក់) | 301.02 | (298.84) | 1,612.19 | -639.5% |
| ឱនភាពទូទៅ (សាច់ប្រាក់) | (1,791.80) | (2,401.63) | 78.92 | -103.3% |
| **III. ហិរញ្ញប្បទាន** | **1,791.80** | **2,401.63** | **(78.92)** | **-103.3%** |
| ១. ហិរញ្ញប្បទានក្រៅស្រុក | 1,810.95 | 390.77 | 286.56 | -26.7% |
| ២. ហិរញ្ញប្បទានក្នុងស្រុក | 93.30 | (76.14) | 122.42 | -260.8% |
| ៣. ប្រតិបត្តិការកំពុងដំណើរការ | (112.45) | 2,087.00 | (487.90) | -123.4% |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ៣÷ស្ថានភាពហិរញ្ញវត្ថុសាធារណៈ (គិតជាប៊ីលានរៀល)*




ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៤. ស្ថានភាពរូបិយវត្ថុ និងឥណទាន

*តារាង ៥÷ ស្ថានភាពរូបិយវត្ថុ (គិតជាប៊ីលានរៀល)*

| បរិយាយ | ត្រីមាសទី៣ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២២ |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **66,803.98** | **57,390.99** | **38,924.32** | **-32.2%** |
| ឥណទេយ្យពីអនិវាសជន | 102,196.44 | 98,337.24 | 92,208.93 | -6.2% |
| ទ្រព្យអកម្មចំពោះអនិវាសជន | (35,392.46) | (40,946.25) | (53,284.61) | 30.1% |
| **ឥណទេយ្យក្នុងស្រុក** | **117,918.31** | **159,673.10** | **197,698.93** | **23.8%** |
| ឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល | (24,421.63) | (19,741.46) | (21,499.10) | 8.9% |
| ឥណទេយ្យចំពោះរដ្ឋាភិបាល | 112.16 | 118.23 | 181.24 | 53.3% |
| ទ្រព្យអកម្មរដ្ឋាភិបាល | (24,533.79) | (19,859.69) | (21,680.34) | 9.2% |
| ឥណទេយ្យសុទ្ធចំពោះវិស័យផ្សេងៗ | 142,339.95 | 179,414.56 | 219,198.03 | 22.2% |
| ឥណទេយ្យចំពោះរដ្ឋាភិបាលថ្នាក់ក្រោមជាតិ | - | - | - | - |
| ឥណទេយ្យចំពោះគ្រឹះស្ថានសាធារណៈមិនមែនហិរញ្ញវត្ថុ | 0.58 | 36.27 | 52.47 | 44.7% |
| ឥណទេយ្យចំពោះវិស័យឯជន | 142,339.37 | 179,378.29 | 219,145.56 | 22.2% |
| **ទ្រព្យអកម្មជារូបិយវត្ថុទូទៅ (M2)** | **132,613.63** | **152,996.61** | **169,403.64** | **10.7%** |
| *ក្នុងនោះជារូបិយបណ្ណបរទេស* | 111,094.25 | 126,408.92 | 141,427.28 | 11.9% |
| រូបិយវត្ថុ (M1) | 38,144.01 | 43,251.27 | 42,721.95 | -1.2% |
| រូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ | 13,199.48 | 14,772.39 | 13,995.96 | -5.3% |
| ប្រាក់បញ្ញើចរន្ត | 24,944.53 | 28,478.88 | 28,725.98 | 0.9% |
| ប្រាក់បញ្ញើផ្សេងទៀត | 94,469.62 | 109,745.34 | 126,681.70 | 15.4% |
| មូលបត្រមិនមែនភាគហ៊ុន | - | - | - | - |
| **ទុនបម្រុងជារូបិយបណ្ណបរទេសដុល (លានដុល្លារអាមេរិក)** | **20,470.24** | **19,693.70** | **17,663.57** | -10.3% |

*ប្រភព: ធនាគារជាតិនៃកម្ពុជា*

*រូបភាព ៤÷ស្ថានភាពរូបិយវត្ថុប្រចាំត្រីមាស*




ប្រភព: ធនាគារជាតិនៃកម្ពុជា

*តារាង ៦÷ ស្ថានភាពឥណទានផ្ដល់ដោយធនាគារពាណិជ្ជ (គិតជាប៊ីលានរៀល)*

| បរិយាយ | ត្រីមាសទី៣ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២២ |
| គ្រឹះស្ថានហិរញ្ញវត្ថុ | 5,464.79 | 6,722.55 | 8,236.65 | 22.5% |
| ធនាគារជាតិនៃកម្ពុជា | - | - | - | - |
| គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | 3,429.08 | 4,923.31 | 6,078.77 | 23.5% |
| គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត | 2,035.71 | 1,799.24 | 2,157.88 | 19.9% |
| គ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ | 86,805.00 | 107,971.12 | 135,658.09 | 25.6% |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 8,717.38 | 11,154.30 | 15,081.43 | 35.2% |
| ឧស្សាហកម្មរ៉ែ | 520.95 | 674.26 | 1,023.06 | 51.7% |
| កម្មន្តសាល | 4,775.80 | 6,223.58 | 7,690.87 | 23.6% |
| ការផ្គត់ផ្គង់សេវាសាធារណៈ | 1,177.07 | 1,926.42 | 1,918.75 | -0.4% |
| សំណង់ | 11,211.18 | 14,733.44 | 17,543.86 | 19.1% |
| ការជួញដូរដុំ | 12,329.50 | 14,710.56 | 18,008.75 | 22.4% |
| ការជួញដូររាយ | 18,475.58 | 23,506.73 | 30,060.41 | 27.9% |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 5,088.75 | 6,945.76 | 8,240.75 | 18.6% |

| បរិយាយ | ត្រីមាសទី៣ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២២ |
| ដឹកជញ្ជូន និងស្តុកបណ្តោះអាសន្ន | 2,930.15 | 3,866.33 | 4,925.44 | 27.4% |
| បណ្តាញព័ត៌មាន និងទូរគមនាគមន៍ | 771.33 | 1,256.44 | 1,060.28 | -15.6% |
| អាជីវកម្មជួល និងភតិសន្យាប្រតិបត្តិការ * | 3,637.69 | 2,558.14 | 2,780.32 | 8.7% |
| ការជួញដូរអចលនទ្រព្យ | 10,318.68 | 12,681.03 | 17,217.73 | 35.8% |
| សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗ | 6,850.94 | 7,734.12 | 10,106.45 | 30.7% |
| តម្រូវការផ្ទាល់ខ្លួន | 25,715.41 | 35,484.67 | 42,518.60 | 19.8% |
| ការឱ្យខ្ចីជាបុគ្គល | 10,913.88 | 15,214.23 | 15,608.33 | 2.6% |
| ការឱ្យខ្ចីតាមបណ្ណឥណទាន | 225.44 | 303.99 | 470.05 | 54.6% |
| ការឱ្យខ្ចីទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន | 14,576.09 | 19,966.45 | 26,440.22 | 32.4% |
| ឥណទានផ្សេងៗ | 1,547.02 | 1,528.63 | 2,436.51 | 59.4% |
| **សរុប** | **119,532.22** | **151,706.97** | **188,849.86** | **24.5%** |
| *ក្នុងនោះជារៀល* | *13,234.48* | *16,720.13* | *20,313.00** | *21.5%* |

ប្រភពៈ ធនាគារជាតិនៃកម្ពុជា, * ទិន្នន័យត្រឹមខែសីហា ឆ្នាំ២០២២

*រូបភាព ៥÷ស្ថានភាពឥណទានផ្តល់ដោយធនាគារពាណិជ្ជប្រចាំត្រីមាស*




ប្រភពៈ ធនាគារជាតិនៃកម្ពុជា

*តារាង ៧÷ ស្ថានភាពឥណទានផ្តល់ដោយមីក្រូហិរញ្ញវត្ថុ (គិតជាប៊ីលានរៀល)*

| បរិយាយ | ត្រីមាសទី៣ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ * | ២០២២ |
| ស្ថាប័នហិរញ្ញវត្ថុ | 34.18 | 31.94 | 46.84 | 46.7% |
| កសិកម្ម | 5,543.10 | 6,298.46 | 6,553.62 | 4.1% |
| កម្មន្តសាល | 274.31 | 493.16 | 660.78 | 34.0% |
| ពាណិជ្ជកម្ម | 6,064.88 | 7,271.16 | 8,634.34 | 18.7% |
| គ្រួសារ | 10,824.83 | 11,122.72 | 12,191.27 | 9.6% |
| សេវាកម្ម | 4,677.41 | 4,699.31 | 5,123.03 | 9.0% |
| ដឹកជញ្ជូន | 1,797.15 | 1,824.63 | 1,705.42 | -6.5% |
| សំណង់ | 1,168.31 | 1,262.72 | 1,706.23 | 35.1% |
| ឥណទានផ្សេងៗ | 531.95 | 413.71 | 567.54 | 37.2% |
| **សរុប** | **30,916.11** | **33,417.80** | **37,189.06** | **11.3%** |

ប្រភព: ធនាគារជាតិនៃកម្ពុជា, *ទិន្នន័យត្រឹមខែសីហា ឆ្នាំ២០២២

*រូបភាព ៦÷ចំណែកនៃឥណទានតាមវិស័យផ្តល់ដោយមីក្រូហិរញ្ញវត្ថុប្រចាំត្រីមាស*







ប្រភព: ធនាគារជាតិនៃកម្ពុជា, *ទិន្នន័យត្រឹមខែសីហា ឆ្នាំ២០២២

## ២.៥. ស្ថានភាពពាណិជ្ជកម្ម

*តារាង ៨÷ ការនាំចូលតាមមុខទំនិញសំខាន់ៗ (គិតជាលានដុល្លារអាមេរិក)*

| មុខទំនិញ | ត្រីមាសទី៣ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២២ |
| ថ្នាំពេទ្យ | 58.90 | 267.03 | 79.51 | -70.2% |
| ភេសជ្ជៈ គ្រឿងស្រវឹង និងបារី | 129.00 | 122.02 | 132.96 | 9.0% |
| ស្ករស និងបឺចេង | 11.55 | 14.69 | 17.42 | 18.6% |
| ប្រេងឆា និងអាហារផ្សេងៗ | 131.18 | 138.82 | 153.67 | 10.7% |
| គ្រឿងសំណង់ | 351.46 | 441.90 | 421.60 | -4.6% |
| គ្រឿងអេឡិចត្រូនិក | 165.09 | 197.71 | 249.35 | 26.1% |
| វាយនភណ្ឌ និងសម្លៀកបំពាក់ | 1,103.11 | 1,351.96 | 1,305.33 | -3.4% |
| យានយន្ត | 241.61 | 285.75 | 482.77 | 69.0% |
| គ្រឿងបង្គុំរថយន្ត | 4.81 | 5.99 | 6.28 | 4.8% |
| បរិក្ខារត្រជាក់ | 19.44 | 21.27 | 17.16 | -19.3% |
| ប្រេងឥន្ធនៈ | 266.63 | 437.23 | 767.44 | 75.5% |
| មាស | - | 628.80 | 1,547.75 | 146.1% |
| ជីកសិកម្ម | 64.62 | 80.37 | 60.32 | -24.9% |
| ផ្សេងៗ | 1,774.65 | 2,452.19 | 2,657.98 | 8.4% |
| **សរុប** | **4,322.05** | **6,445.72** | **7,899.54** | **22.6%** |

ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ៧៖ ទំហំនាំចូលគ្រឿងសំណង់, ប្រេងឥន្ធនៈ, យានយន្ត, វាយនភណ្ឌនិងសម្លៀកបំពាក់ (លានដុល្លារអាមេរិក)*




ប្រភព: ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ៨៖ ស្ថានភាពនាំចូលពីទីផ្សារអន្តរជាតិ (គិតជាលានដុល្លារអាមេរិក)*




ប្រភព: ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*តារាង ៩÷ មុខទំនិញនាំចេញ (គិតជាលានដុល្លារអាមេរិក)*

| មុខទំនិញ | ត្រីមាសទី៣ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២២ |
| សម្លៀកបំពាក់ | 2,084.61 | 2,591.84 | 2,664.92 | 2.8% |
| ស្បែកជើង | 242.98 | 360.17 | 477.91 | 32.7% |
| កាបូប | 233.45 | 418.88 | 436.81 | 4.3% |
| វាយនភណ្ឌផ្សេងៗ | 78.94 | 89.94 | 62.24 | -30.8% |
| គ្រឿងបង្គុំអេឡិចត្រូនិក | 43.31 | 55.71 | 40.99 | -26.4% |
| គ្រឿងបង្គុំរថយន្ត | 35.34 | 36.63 | 38.41 | 4.9% |
| កង់ | 138.24 | 178.48 | 243.80 | 36.6% |
| ឈើមូល | 2.08 | 1.68 | 1.25 | -25.6% |
| ឈើកែច្នៃ (Veneer) | 0.53 | 1.07 | 0.10 | -90.8% |
| ក្តារបន្ទះ | 44.78 | 75.03 | 44.55 | -40.6% |
| ឈើកែច្នៃផ្សេងទៀត | 47.68 | 72.67 | 66.18 | -8.9% |
| អង្ករ | 62.25 | 81.83 | 87.45 | 6.9% |
| ដំឡូងមី | 3.05 | 3.57 | 1.50 | -58.1% |
| ពោតក្រហម | 0.14 | 0.05 | 0.01 | -80.0% |
| សណ្តែក | 0.10 | 0.00 | 0.00 | -100.0% |
| ចេក | 26.76 | 37.74 | 33.57 | -11.1% |
| ស្វាយ | 0.73 | 1.21 | 0.00 | -100.0% |
| ស្វាយចន្ទី | 0.93 | 1.36 | 0.64 | -52.8% |
| កៅស៊ូ | 82.11 | 108.23 | 91.08 | -15.8% |
| ស្ករ | 11.73 | 8.21 | 6.44 | -21.6% |
| ផលិតផលជលផល | 0.09 | 0.08 | 0.10 | 34.8% |
| កសិផលផ្សេងទៀត | 4.00 | 7.86 | 7.64 | -2.7% |
| បារី | 1.76 | 1.80 | 2.33 | 30.0% |
| ខ្សែភ្លើង និងបង្គុំខ្សែភ្លើង | 38.33 | 63.93 | 88.01 | 37.7% |
| សំបកកំប៉ុង និងគម្របកំប៉ុង | 0.00 | 0.00 | 0.20 | 10656.3% |
| មាស | 1,630.24 | 22.24 | 46.94 | 111.1% |
| ផ្សេងៗ | 710.93 | 1,139.02 | 1,171.54 | 2.9% |
| **សរុប** | **5,525.09** | **5,359.23** | **5,614.61** | **4.8%** |

ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ៩÷ ស្ថានភាពមុខទំនិញនាំចេញសំខាន់ៗ (គិតជាលានដុល្លារអាមេរិក)*




ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ១០÷ ស្ថានភាពនាំចេញទៅទីផ្សារអន្តរជាតិ (គិតជាលានដុល្លារអាមេរិក)*




ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៦. ការវិនិយោគឯកជន

*តារាង ១០÷ ស្ថិតិវិនិយោគវិស័យឯកជន (អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)*

| ការអនុញ្ញាតវិនិយោគ | ឯកតា | ត្រីមាសទី៣ | | | ការប្រែប្រួល |
|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | ២០២២ |
| **គម្រោងវិនិយោគសរុប** | **គម្រោង** | **38** | **47** | **52** | **10.6%** |
| **បង្កើតការងារសរុប** | **នាក់** | **27,034** | **35,143** | **40,274** | **14.6%** |
| **ទុនវិនិយោគសរុប** | **លានដុល្លារអាមេរិក** | **3,788.19** | **389.06** | **460.77** | **18.4%** |
| ការវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស | | | | | |
| គម្រោងវិនិយោគ | គម្រោង | 8 | 10 | 19 | 90.0% |
| បង្កើតការងារ | នាក់ | 2,398 | 4,012 | 8,131 | 102.7% |
| ទុនវិនិយោគលើវិស័យ | លានដុល្លារអាមេរិក | 33.84 | 82.66 | 194.47 | 135.3% |
| កសិកម្ម | លានដុល្លារអាមេរិក | - | - | - | - |
| ថាមពល | លានដុល្លារអាមេរិក | - | - | - | - |
| ឧស្សាហកម្ម | លានដុល្លារអាមេរិក | 33.84 | 82.66 | 194.47 | 135.3% |
| សេវាកម្ម | លានដុល្លារអាមេរិក | - | - | - | - |
| ទេសចរណ៍ | លានដុល្លារអាមេរិក | - | - | - | - |
| ការវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេស | | | | | |
| គម្រោងវិនិយោគ | គម្រោង | 30 | 37 | 33 | -10.8% |
| បង្កើតការងារ | នាក់ | 24,636 | 31,131 | 32,143 | 3.3% |
| ទុនវិនិយោគលើវិស័យ | លានដុល្លារអាមេរិក | 3,754.36 | 306.40 | 266.30 | -13.1% |
| កសិកម្ម | លានដុល្លារអាមេរិក | 31.71 | 14.03 | - | -100.0% |
| ថាមពល | លានដុល្លារអាមេរិក | 39.85 | 13.29 | - | -100.0% |
| ឧស្សាហកម្ម | លានដុល្លារអាមេរិក | 167.66 | 279.08 | 167.04 | -40.1% |
| សេវាកម្ម | លានដុល្លារអាមេរិក | - | - | 64.00 | - |
| ទេសចរណ៍ | លានដុល្លារអាមេរិក | 3,515.13 | - | 35.25 | - |

ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC), សម្គាល់ការអនុញ្ញាតវិនិយោគសរុប÷រួមបញ្ចូលការពង្រីកគម្រោងក្រៅតំបន់សេដ្ឋកិច្ចពិសេស

*រូបភាព ១១÷ស្ថានភាពវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេស*




ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)

## ២.៧. ស្ថានភាពទេសចរណ៍

*តារាង ១១÷ ចំនួនភ្ញៀវទេសចរអន្តរជាតិ*

| បរិយាយ | ឯកតា | ត្រីមាសទី៣ | | | ការប្រែប្រួល |
|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | ២០២២ |
| **សរុប** | **នាក់** | **64,854** | **29,114** | **759,010** | 2507.0% |
| តាមផ្លូវអាកាស | នាក់ | 36,325 | 16,801 | 228,252 | 1258.6% |
| ភ្នំពេញ | នាក់ | 29,351 | 16,677 | 179,441 | 976.0% |
| សៀមរាប | នាក់ | 7 | - | 42,737 | - |
| កងកេង | នាក់ | 6,967 | 124 | 6,074 | 4798.4% |
| តាមផ្លូវគោក និងផ្លូវទឹក | នាក់ | 28,529 | 12,313 | 530,758 | 4210.5% |
| ផ្លូវគោក | នាក់ | 28,524 | 12,313 | 527,065 | 4180.6% |
| ផ្លូវទឹក | នាក់ | 5 | - | 3,693 | - |

ប្រភព: ក្រសួងទេសចរណ៍

*រូបភាព ១២៖ កំណើនភ្ញៀវទេសចរអន្តរជាតិ (គិតជា %)*




ប្រភព៖ ក្រសួងទេសចរណ៍

*រូបភាព ១៣៖ កំណើនភ្ញៀវទេសចរអន្តរជាតិពីតំបន់នីមួយៗ (គិតជា %)*




ប្រភព៖ ក្រសួងទេសចរណ៍

## ២.៨. ស្ថានភាពសំណង់

*តារាង ១២÷ គម្រោងអនុញ្ញាតសាងសង់*

| គម្រោងសុំសាងសង់តាមប្រភេទសំណង់ | ឯកត្តា | ត្រីមាសទី៣ | | | ការប្រែប្រួល |
|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | ២០២២ |
| សំណង់សាធារណៈ | គម្រោង | 15 | 11 | 14 | 27.3% |
| សំណង់លំនៅឋាន និងភូមិគ្រឹះ | គម្រោង | 1,056 | 837 | 1,014 | 21.1% |
| សំណង់ឧស្សាហកម្ម | គម្រោង | 57 | 68 | 72 | 5.9% |
| សំណង់ពាណិជ្ជកម្ម | គម្រោង | 70 | 91 | 68 | -25.3% |
| សំណង់ទេសចរណ៍ | គម្រោង | 19 | 21 | 6 | -71.4% |
| សំណង់វិនិយោគផ្សេងៗ | គម្រោង | - | - | 1 | - |
| **សរុប** | **គម្រោង** | **1,217** | **1,028** | **1,175** | **14.3%** |
| **តម្លៃគម្រោង** | **លានដុល្លារអាមេរិក** | **2,025.3** | **1,885.6** | **752.8** | **-60.1%** |

ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

*រូបភាព ១៤÷ ចំណែកនៃផ្ទៃក្រឡាសាងសង់តាមប្រភេទ (គិតជា %)*




ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

*តារាង ១៣÷ ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យមប្រចាំត្រីមាស)*

| មុខទំនិញ | ឯកតា | ទីផ្សារ | ត្រីមាសទី៣ | | | ការប្រែប្រួល |
|---|---|---|---|---|---|---|
| | | | ២០២០ | ២០២១ | ២០២២ | ២០២២ |
| អង្ករ (បាក់៥%) | ដុល្លារអាមេរិក/ តោន | បាងកក | 497.33 | 405.67 | 429.3 | 5.8% |
| ប្រេងឆៅ | ដុល្លារអាមេរិក/ ធុង | ក្រុងឡុងដ៍ | 42.04 | 71.65 | 96.4 | 34.6% |
| កៅស៊ូ | ដុល្លារអាមេរិក/ តោន | សិង្ហបុរី | 1,297.40 | 1,654.37 | 1,447.0 | -12.5% |
| មាស | ដុល្លារអាមេរិក/ អោន | ក្រុងឡុងដ៍ | 2,098.12 | 1,963.24 | 1,893.7 | -3.5% |
| ពោតក្រហម | ដុល្លារអាមេរិក/ តោន | ស៊ីកាហ្គោ | 155.99 | 256.89 | 308.4 | 20.1% |
| សណ្តែកសៀង | ដុល្លារអាមេរិក/ តោន | ស៊ីកាហ្គោ | 396.34 | 581.26 | 671.3 | 15.5% |
| ប្រេងដូង | ដុល្លារអាមេរិក/ តោន | រ៉ុតធើដាំ | 967.93 | 1,520.91 | 1,391.1 | -8.5% |
| ស្ករស | ដុល្លារអាមេរិក/ តោន | ក្រុងឡុងដ៍ | 381.89 | 384.97 | 329.0 | -14.5% |

ប្រភពៈ គេហទំព័រធនាគារពិភពលោក (*www.worldbank.org*)

*រូបភាព១៥ ÷ ទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យមប្រចាំត្រីមាស)*




ប្រភពៈ គេហទំព័រធនាគារពិភពលោក (*www.worldbank.org*)

*តារាង ១៤÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យមប្រចាំត្រីមាស, ឆ្នាំគោល ២០១០=១០០)*

| មុខទំនិញ | ត្រីមាសទី៣ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២២ |
| **មិនមែនថាមពល** | **84.85** | **112.49** | **116.1** | **3.2%** |
| ផលិតផលកសិកម្ម | 86.56 | 107.85 | 118.2 | 9.6% |
| ម្ហូបអាហារ | 90.98 | 120.45 | 137.2 | 13.9% |
| ឈើ | 86.97 | 90.45 | 76.0 | -15.9% |
| លោហៈធាតុ | 82.56 | 120.13 | 100.6 | -16.2% |
| ជីគីមី | 74.22 | 129.06 | 215.2 | 66.7% |

ប្រភពៈ គេហទំព័រធនាគារពិភពលោក (www.worldbank.org)

*រូបភាព ១៦ ÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យមប្រចាំត្រីមាស, ឆ្នាំគោល ២០១០=១០០)*




*ចំណាំ÷អាហារ (ធញ្ញជាតិ, ប្រេងឆា និងអាហារផ្សេងៗ), ភេសជ្ជៈ (កាកាវ, កាហ្វេ និងតែ), វត្ថុធាតុដើម (ឈើមូល, កប្បាស, កៅស៊ូ និងថ្នាំជក់)*

ប្រភពៈ គេហទំព័រធនាគារពិភពលោក (www.worldbank.org),

*តារាង ១៥÷ អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិធៀបនឹងដុល្លារអាមេរិក (ជាមធ្យមប្រចាំត្រីមាស)*

| រូបិយបណ្ណ | ត្រីមាសទី៣ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២២ |
| ជប៉ុន (Yen) | 105.48 | 109.71 | 139.36 | 27.0% |
| ហុងកុង (Dollar) | 7.75 | 7.78 | 7.85 | 0.9% |
| សិង្ហបុរី (Dollar) | 1.37 | 1.35 | 1.40 | 4.0% |
| ម៉ាឡេស៊ី (Ringgit) | 4.19 | 4.20 | 4.52 | 7.5% |
| ហ្វីលីពីន (Peso) | 48.63 | 50.01 | 56.89 | 13.8% |
| ថៃ (Baht) | 31.27 | 32.71 | 36.96 | 13.0% |
| ឥណ្ឌូនេស៊ី (Rupiah) | 14,706.23 | 14,409.87 | 14,982.97 | 4.0% |
| កូរ៉េខាងត្បូង (Won) | 1,180.81 | 1,152.66 | 1,360.00 | 18.0% |
| តៃវ៉ាន់ (Dollar) | 29.21 | 27.87 | 30.70 | 10.2% |
| ចិន (Yuan Renminbi) | 6.88 | 6.46 | 6.94 | 7.3% |
| ឡាវ (Kip) | 8,955.71 | 9,341.16 | 15,409.10 | 65.0% |
| វៀតណាម (Dong) | 23,138.57 | 22,860.90 | 23,526.83 | 2.9% |
| ឥណ្ឌា (Rupee) | 73.82 | 73.84 | 80.26 | 8.7% |
| រុស្ស៊ី (Ruble) | 75.37 | 73.27 | 59.85 | -18.3% |
| អូស្ត្រាលី (Dollar) | 1.38 | 1.36 | 1.48 | 8.5% |
| អង់គ្លេស (Pound) | 0.76 | 0.72 | 0.86 | 20.0% |
| អឺរ៉ុប (Euro) | 0.85 | 0.84 | 1.00 | 18.8% |

ប្រភព: *គេហទំព័រអូអ៊ែនអេ*(www.oanda.com)